**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ..០៣៩...ស.ខ៧

# សេចក្តីណែនាំ

## ស្តីពី

## នីតិវិធីដាក់ខ្លួនឲ្យនៅដាច់ដោយឡែកក្នុងរយៈពេល ១៤ថ្ងៃ ដើម្បីបង្ការ និងទប់ស្កាត់ជំងឺកូវីដ១៩ នៅតាមផ្ទះជាលក្ខណៈបុគ្គល

យោងតាមសារាចរណែនាំស្តីពីវិធានការបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺ COVID-19 របស់រាជរដ្ឋាភិបាល លេខ ០១ សរណន ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០ ក្រសួងសុខាភិបាលសូមធ្វើការណែនាំដល់បុគ្គលដែលត្រូវធ្វើចត្តាឡីស័ក នៅក្នុងផ្ទះរយៈពេល១៤ថ្ងៃ នៅក្នុងបន្ទប់ដាច់ដោយឡែក ដូចខាងក្រោម៖

-បន្ទប់ត្រូវមានខ្យល់ចេញចូលល្អ។ ប្រសិនបើបន្ទប់តែមួយមិនអាចធ្វើបាន ត្រូវរក្សាចម្ងាយយ៉ាងហោចណាស់ពីរម៉ែត្រពីសមាជិកគ្រួសារផ្សេងទៀត។

-កាត់បន្ថយការប្រើប្រាស់កន្លែងទំនេររួម និង កាត់បន្ថយកន្លែងរស់នៅរួមគ្នា (ផ្ទះបាយ បន្ទប់ទឹក ជាដើម)

-ក្នុងអំឡុងពេល១៤ថ្ងៃនេះ ត្រូវតាមដានសុខភាពផ្ទាល់ខ្លួន និងរោគសញ្ញា រួមមាន កំដៅ ក្អក ឈឺបំពង់កហត់ ឬពិបាកដកដង្ហើម ឬរោគសញ្ញាផ្សេងៗទៀត។

-បើមានរោគសញ្ញាណាមួយខាងលើ ឬបញ្ហាសុខភាពផ្សេងៗ ត្រូវរាយការណ៍ជាបន្ទាន់ទៅកាន់ទូរស័ព្ទទាន់ហេតុការណ៍ ១១៥ ឬអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ឬប្រធានមន្ទីរសុខាភិបាលរាជធានី-ខេត្ត ឬប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ឬប្រធានមន្ទីរពេទ្យបង្អែកដែលនៅជិតផ្ទះរបស់លោក អ្នក ដូចមានបញ្ជីលេខទូរស័ព្ទទំនាក់ទំនងជូនភ្ជាប់មកជាមួយ។

-អនុវត្តអនាម័យលាងដៃឲ្យបានញឹកញាប់ ជាពិសេសបន្ទាប់ពីប៉ះពាល់ជាមួយទឹករំអិលផ្លូវដង្ហើម។

-ខ្ទប់ច្រមុះ និងមាត់ ដោយប្រើកែងដៃ ឬក្រដាសអនាម័យ នៅពេលក្អក ឬកណ្តាស់ រួចបោះចោលក្រដាសអនាម័យនោះចោលភ្លាមទៅក្នុងធុងសម្រាមត្រឹមត្រូវ។

-ត្រូវសម្អាតបន្ទប់ស្នាក់នៅ និងបន្ទប់ទឹកឲ្យបានជាប្រចាំ។

-ត្រូវសម្អាតជានិច្ច និងបោកគក់សម្លៀកបំពាក់ ស្រោមពូកខ្នើយ និងគ្រឿងបរិក្ខារប្រើប្រាស់ផ្សេងៗ។

អាជ្ញាធរមូលដ្ឋាន និងមន្រ្តីសុខាភិបាលមូលដ្ឋាន ត្រូវតាមឃ្លាំមើលជានិច្ច ដើម្បីឲ្យប្រាកដថា បុគ្គលដែលត្រូវបានធ្វើចត្តាឡីស័កដោយខ្លួនឯង អនុវត្តបានត្រឹមត្រូវតាមការណែនាំនេះ។

ទទួលបានសេចក្តីណែនាំនេះ សូមអាជ្ញាធរ និងអង្គភាពពាក់ព័ន្ធ ព្រមទាំងសាធារណៈ ចូលរួមសហការអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម_ប៊ុនហេង**

កន្លែងទទួល៖

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-អភិបាលរាជធានី-ខេត្ត

-មន្ទីរសុខាភិបាលរាជធានី-ខេត្ត

-ឯកសារ-កាលប្បវត្តិ